និយ័តករបរធនបាលកិច្ច
TRUST REGULATOR

# សេចក្តីប្រកាសព័ត៌មាន

## វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីនៃនិយ័តករបរធនបាលកិច្ច និងនិយ័តករមូលបត្រកម្ពុជា
## ស្តីពី
## "នីតិវិធី និងគន្លឹះសំខាន់ៗ ដើម្បីដាក់ពាក្យស្នើសុំអាហារូបករណ៍ ម៉ាណាគី ណូវែលហ្សេឡង់"

ថ្ងៃពុធ ៥ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
ត្រូវនឹងថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣
នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

នារសៀលថ្ងៃពុធ ៥ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), និយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) និងអាហារូបករណ៍ ម៉ាណាគី ណូវែលហ្សេឡង់ បានសហការរៀបចំវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីនៃ **ន.ប.ធ.** និង **ន.ម.ក.** ស្តីពី "**នីតិវិធី និងគន្លឹះសំខាន់ៗ ដើម្បីដាក់ពាក្យស្នើសុំអាហារូបករណ៍ Manaaki New Zealand Scholarships (MNZS)**" ដោយមានការគាំទ្រពីក្រុមហ៊ុន អាយឌីភី អេឌ្យូខេសិន (ខេមបូឌា) លីមីធីត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ **ន.ម.ក.**, **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង**លោក** Ashley Irving នាយកសាលានៃមជ្ឈមណ្ឌល ACE ។

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីចែករំលែកព័ត៌មានលម្អិត និងបទពិសោធន៍អំពីការដាក់ពាក្យស្នើសុំអាហារូបករណ៍ ដើម្បីបន្តការសិក្សាថ្នាក់អនុបណ្ឌិត និងបណ្ឌិតនៅប្រទេសណូវែលហ្សេឡង់, ការរៀបចំឯកសារសម្រាប់ដំណើរការសិក្សានៅសាកលវិទ្យាល័យនៅប្រទេសណូវែលហ្សេឡង់, ព័ត៌មានសម្រាប់ការធ្វើតេស្ត IELTS និងគន្លឹះសំខាន់ៗសម្រាប់មន្ត្រីនៃ **ន.ប.ធ.** និង **ន.ម.ក.** ក្នុងការត្រៀមខ្លួនដាក់ពាក្យស្នើសុំអាហារូបករណ៍ MNZS ។

វគ្គបណ្តុះបណ្តាលខាងលើនេះ មានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.ប.ធ.** និង **ន.ម.ក.** សរុបចំនួន **១២២ រូប** ព្រមទាំងមានការចូលរួមពីវាគ្មិនកិត្តិយសមកពី **ក្រុមហ៊ុន អាយ ឌី ភី អេឌ្យូខេសិន (ខេមបូឌា) លីមីធីត** និងអតីតនិស្សិត ដែលទទួលបានអាហារូបករណ៍ MNZS ផងដែរ។